# នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឆាំង យុ ធ្វើសក្ខីកម្មនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ដោយ វេនឌល ឌីហ្វាល់កូ**

**ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១២**

*កែសម្រួលដោយ ផា ផល្លា*

*“បានអានឯកសារមួយសន្លឹក ដូចរើសបានបាយមួយគ្រាប់ពីក្នុងភក់អ៊ីចឹង វាផ្អែមណាស់”*
*--ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា*

នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១២នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបន្តសវនាការដោយស្តាប់សក្ខីកម្មរបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ចៅក្រម និល ណុន ផ្តើមសួរសំណួរទៅលោក ឆាំង យុ នូវសំណួរបឋមមួយចំនួន។ លោក ឆាំង យុ បានឆ្លើយថា លោកទទួលបានសញ្ញាបត្រថ្នាក់អនុបណ្ឌិត ហើយគាត់អាចនិយាយភាសាខ្មែរ អង់គ្លេស ចំណែកភាសាបារាំង ថៃ និង ឡាវ បេះខ្លះៗ ។

ក្រោយមក ចៅក្រម និល ណុន បានរំឭកទៅគ្រប់ភាគីទាំងអស់ឲ្យសួរតែរឿងរ៉ាវទាក់ទងទៅនឹងឯកសារដែលផ្តល់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជាបានហើយ និងត្រូវផ្តោតទៅលើសំណួរទូទៅជាជាងសួរនាំអំពីឯកសារជាក់លាក់ណាមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ភាគីព្រះរាជអាជ្ញាជាអ្នកចាប់ផ្តើមសួរសំណួរមុនគេ ។

## ព្រះរាជអាជ្ញាសួរសំណួរ

ព្រះរាជអាជ្ញាជាតិ ចាន់ តារាស្មី ចាប់ផ្តើមសួរសំណួរអំពីប្រវត្តិអប់រំរបស់ លោក ឆាំង យុ ។ លោក ឆាំង យុ បានឆ្លើយថា លោកទទួលបានសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រនយោបាយ ពីសាកលវិទ្យាល័យដាឡាស់ ក្នុងរដ្ឋតិចសាស សហរដ្ឋអាមេរិក ។ លោកក៏ទទួលបានការបណ្តុះបណ្តាលផ្នែកឯកសារនៅសាកលវិទ្យាល័យយែល ហើយបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនិងកិច្ចប្រជុំខ្លីៗជាច្រើនផង ។

ពេលសួរអំពីកាលពីពេលដែលគាត់រស់នៅប្រទេសថៃ លោក ឆាំង យុ បានឆ្លើយថា លោករស់នៅក្នុងជំរំជនភៀសខ្លួន ។ កាលនៅប្រទេសថៃ លោកធ្វើការខាងអង្គការមនុស្សធម៌ ហើយកាល

នោះ លោកបានរៀនភាសាថៃ និងអង់គ្លេស។ នៅពេលសួរថា តើគាត់អាចទៅកាន់សហរដ្ឋអាមេរិកដោយរបៀបណា លោក ឆាំង យុ បានឆ្លើយថា លោកចង់ទៅសហរដ្ឋអាមេរិកដោយខ្លួនឯងដោយមិនចាំបាច់ជាប់ពាក់ព័ន្ធជាមួយគ្រួសារ ទោះបីជាលោកមានបងប្អូនរស់នៅសហរដ្ឋអាមេរិកហើយក៏ដោយ។ លោកចង់ទៅអាមេរិក ព្រោះលោកមានបងប្អូនច្រើនធ្វើការកាលពីជំនាន់ លន់ នល់ ដែលគាំទ្រដោយសហរដ្ឋអាមេរិក កាលនោះមានអ្នកកាសែតជនជាតិអាមេរិកជាច្រើនរូបតែងមកលេងផ្ទះរបស់គាត់ក្នុងទីក្រុងភ្នំពេញ ពេលដែលលោកនៅក្មេង។ លោកស្រលាញ់អ្នកកាសែត។ ក្នុងនោះមានអ្នកកាសែតស្រីខ្ពស់ម្នាក់ដែលលោកស្រាលាញ់ជាងគេ។

លោក ឆាំង យុ បានបន្តថា លោកបានជ្រើសរើសសហរដ្ឋអាមេរិកជាគោលដៅដែលលោកចង់ទៅពេលដែលរស់នៅប្រទេសថៃ ហើយពេលដែលប្រធានរបស់លោកសួរថា តើលោកចង់ទៅរដ្ឋមួយណានៅសហរដ្ឋអាមេរិក លោក ឆាំង យុ បានឆ្លើយថា លោកចង់ទៅរដ្ឋដែលប្រធានាធិបតី ចន កេណ្ណឺឌី ស្លាប់ ព្រោះប្រធានាធិបតីរូបនេះ គឺជាវីរៈបុរសក្នុងចិត្តរបស់លោក ដោយសារតែលោកជាអ្នកលើកកម្ពស់នូវការគោរពសិទ្ធមនុស្ស។ ហេតុដូច្នេះហើយលោក ឆាំង យុ ចង់ទៅក្រុងដាឡាស់ រដ្ឋតិចសាស់។

ចៅក្រម និល ណុន បាននិយាយកាត់និងស្នើទៅព្រះរាជអាជ្ញាឲ្យសួរសំណួរទាក់ទងទៅនឹងខ្លឹមសារឯកសារ ជៀសវាងការសួរសំណួរនាំមុខ។ ក្រោយមក ចាន់ តារាស្មី បានសួរទៅលោក ឆាំង យុ ថា តើពេលណាទើបលោកត្រលប់មកប្រទេសកម្ពុជាវិញ? លោក ឆាំង យុ បានឲ្យដឹងថា លោកត្រលប់មកប្រទេសកម្ពុជាវិញពេលដែលលោកមកធ្វើការជាមួយអ៊ុនតាក់ ពេលនោះគាត់ប្រចាំការនៅខេត្តកំពង់ស្ពឺ។ ក្រោយពីចប់ការងាររួចមក លោកបានត្រលប់ទៅសហរដ្ឋអាមេរិកវិញ និងធ្វើការនៅវិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិ។

ក្រោយមក លោក ឆាំង យុ ត្រូវបានសួរអំពីពេលដែលលោកចាប់ផ្តើមមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោក ឆាំង យុ បានបកស្រាយថា រឿងរ៉ាវនេះវាវែងឆ្ងាយណាស់ ហើយដំបូងកិច្ចការនេះចាប់ផ្តើមដោយសាស្ត្រាចារ្យ ហ្រ្កេកហ្គោរី ស្តេនតុន។ លោក ឆាំង យុ បាននិយាយថា សាស្ត្រាចារ្យ ហ្រ្កេកហ្គោរី ស្តេនតុន ជាអ្នកចាប់ផ្តើមកិច្ចការស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាក្នុងទសវត្សរ៍៨០ ដែលជាផ្នែកមួយនៃកិច្ចខំប្រឹងប្រែងក្នុងការស៊ើបអង្កេតឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម។ ក្រោយមក មានអ្នកស្រាវជ្រាវជាច្រើនទៀតដូចជា បេន ឃៀនិន, ដាវីដ ឆេនដ៏ល័រ និង ស្ទីវហេឌើ ចាប់ផ្តើមធ្វើការស៊ើបអង្កេតពីប្រវត្តិខ្មែរក្រហម។ លោក ឆាំង យុ បន្តទៀតថា លោកបានឮពីគម្រោងស្រាវជ្រាវរបស់សាស្ត្រាចារ្យ ហ្រ្កេកហ្គោរី ស្តេនតុន ក្នុងឆ្នាំ១៩៨៦-១៩៨៧

ហើយលោកក៏មានចំណាប់អារម្មណ៍ស្រាវជ្រាវពីរបបខ្មែរក្រហមដែរ ។ ក្នុងឆ្នាំ១៩៨៩ លោកបានចូលរួមយុទ្ធនាការអន្តរជាតិមួយ ក្នុងរដ្ឋគិចសាស់ ដើម្បីការពារពីការវិលត្រលប់របស់ខ្មែរក្រហមក្នុងប្រទេសកម្ពុជា ។ ក្រេក អេនេសាន់ ដែលធ្វើការនៅការិយាល័យសហព្រះរាជអាជ្ញាក៏ដឹងពីយុទ្ធនាការនេះដែរ ។ លោក ឆាំង យុ បានបញ្ជាក់ថា គោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺដើម្បីចងក្រងឯកសារខ្មែរក្រហម ក្នុងគោលបំណងស្វែងរកការបង្រួបបង្រួមជាតិនៅប្រទេសកម្ពុជា ។ លោកបានពន្យល់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលដៅយុទ្ធសាស្ត្រចំនួនបី ៖

ទីមួយ គឺជួយបង្កើតឲ្យមានតុលាការដើម្បីស្វែងរកការពិត ទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។

ទីពីរ គឺការអប់រំអំពីរឿងរ៉ាវពិតដែលបានកើតឡើងក្នុងរបបខ្មែរក្រហមដល់ក្មេងជំនាន់ក្រោយ និងទីបី គឺបង្កើតវិទ្យាស្ថានអចិន្ត្រៃយ៍មួយដើម្បីសិក្សាពីរបបខ្មែរក្រហម ។

ក្រោយមក ព្រះរាជអាជ្ញាបានសួរអំពីប្រធាននិងសៀវភៅមួយចំនួនដែលបោះពុម្ពដោយលោក ឆាំង យុ ហើយលោកបានឆ្លើយថា លោកមិនបានសរសេរអត្ថបទនិងបានបោះពុម្ពសៀវភៅច្រើនទេ ព្រោះលោករវល់កិច្ចការប្រចាំថ្ងៃនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ទាក់ទងនឹងការប្រជុំ និងវគ្គបណ្តុះបណ្តាលខ្លីៗ លោក ឆាំង យុ បាននិយាយថា លោកបានធ្វើដំណើរទៅប្រទេសជាច្រើនដើម្បីចូលរួមកិច្ចប្រជុំនានា ហើយលោកបាននិយាយពីបញ្ហាខ្មែរក្រហម ។ មានអត្ថបទមួយ លោកបាននិយាយថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមគួរតែធ្វើនៅប្រទេសកម្ពុជាមិនមែននៅទីក្រុងឡាអេទេ ។ លោក ឆាំង យុ បានឲ្យដឹងថា លោកត្រូវបានសម្ភាសដោយសារព័ត៌មានជាតិជាច្រើន ហើយអត្ថបទមួយចំនួនអាចរកបានដោយគ្រាន់តែវាយពាក្យ “Youk Chhang” នៅក្នុង Google ។ ក្រោយមក លោក ឆាំង យុ បានរាយនាមអត្ថបទដ៏វែង ។

បន្ទាប់មក ព្រះរាជអាជ្ញាបានសួរអំពីប្រភពថវិការ និងម្ចាស់ជំនួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ឆាំង យុ បានឲ្យដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានជួយជាថវិការដោយម្ចាស់ជំនួយជាច្រើន ហើយសហរដ្ឋអាមេរិក គឺជាម្ចាស់ជំនួយដ៏ធំជាងគេ ។ លោកមានប្រសាស៍ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានថវិការរាជទ័យទានចំនួនបួនលានដុល្លាសហរដ្ឋអាមេរិក ។ លោកបាននិយាយទៀតថា រដ្ឋាភិបាលប្រទេសស៊ុយអែតជាអ្នកជួយឧបត្ថមថវិការសំខាន់មួយដែរ ថវិការចំនួន៣សែនដុល្លា ត្រូវបានចំណាយសម្រាប់ថតចម្លងឯកសារដើម្បីផ្តល់មកសាលាក្តីខ្មែរក្រហមនេះ ហើយថវិការនេះបានមកពីប្រទេសស៊ុយអែត ។ ក្រោយមក លោក ឆាំង យុ បានរៀបរាប់ឈ្មោះប្រទេសមួយចំនួនដែលបានផ្តល់ថវិការមកមជ្ឈមណ្ឌលឯកសារកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំកន្លងមក ។ មជ្ឈ

មណ្ឌលឯកសារកម្ពុជាមានក្រុមគណនេយ្យឯករាជ្យរបស់ខ្លួន ហើយរាល់ការចំណាយត្រូវបានធ្វើសវនកម្មរៀងរាល់ឆ្នាំ មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានរកឃើញថាមានតម្លាភាពក្នុងការចាយវាយតាមរយៈរបាយការណ៍របស់សវនកម្មនេះ ។ USAID គឺតម្រូវឲ្យមានតម្រូវការច្រើន ពេលផ្ដល់ជំនួយមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ឆាំង យុ បានសង្កត់ធ្ងន់ថា មានតែប្រទេសបារាំងមួយគត់ដែលមិនបានផ្ដល់ជំនួយមកមជ្ឈមណ្ឌលឯកសារកម្ពុជាសោះ ។

ក្រោយមក ព្រះរាជអាជ្ញាបានសួរអំពីសកម្មភាពមួយចំនួនដែលកំពុងតែធ្វើការជាមួយស្ថាប័នដទៃទៀត ។ លោក ឆាំង យុ បានឆ្លើយតបថា មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាសមាជិកមួយរបស់ “Affinity Group” ដែលជាស្ថាប័នចងក្រងឯកសារ ។ ក្រុមនេះត្រូវជួបគ្នាជារៀងរាល់ឆ្នាំ ហើយសមាជិកមកពីប្រទេសកាតាម៉ាឡា អ៊ីរ៉ាក់ រវ៉ាន់ដា ភូមា និងប្រទេសដែលធ្លាប់ជួបជម្លោះផ្សេងទៀត ។

លោក ឆាំង យុ បានផ្ដល់សក្ខីកម្មថា គាត់ធ្លាប់ធ្វើដំណើរទៅទីក្រុងឡាអេ ដែលនៅទីនោះគាត់បានទៅមើលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ ក្នុងពេលនោះ គាត់អស់សង្ឃឹម ដោយសារតែគាត់ឃើញបុគ្គលិកដែលធ្វើការនៅទីនោះសុទ្ធតែមកពីបស្ចិមប្រទេស ទោះបីជានោះជាតុលាការអន្តរជាតិក៏ដោយ ។ លោកបានសួរទៅអ្នកធ្វើការនៅទីនោះថា តើប្រជាជនកម្ពុជាអាចទទួលបានយុត្តិធម៌ពីបទឧក្រិដ្ឋខ្មែរក្រហមដោយរបៀបណា? អ្នកធ្វើការនៅទីនោះបានប្រាប់មកលោកថា រង់ចាំមានតុលាការសិន ។

លោក ឆាំង យុ បានបញ្ជាក់ផងដែរ លោកបានចូលរួមក្នុងកិច្ចប្រជុំជាច្រើនទាក់ទងទៅនឹងយុត្តិធម៌អន្តរកាល ហើយលោកក៏មិនពេញចិត្តដែរដោយសារតែស្ត្រីមិនសូវមានតួនាទីនៅក្នុងតុលាការនេះទេ ។ អំឡុងពេលនេះ លោក ឆាំង យុ បានសម្រេចចិត្តថា ខណៈពេលដែលប្រជាជនកម្ពុជាស្វែងរកជំនួយពីបរទេសក្នុងការស្វែងរកយុត្តិធម៌ ជនរងគ្រោះក៏អាចសម្រេចចិត្តខ្លួនឯងដែរថា តើត្រូវជ្រើសរើសអំពើយុត្តិធម៌នោះដោយរបៀបណា?

លោក ម៉ៃឃើល ខណាវ៉ាស មេធាវីអន្តរជាតិរបស់ អៀង សារី បានក្រោកឈរ និងបានបញ្ជាក់ទៅកាន់អង្គជំនុំជម្រះថា អ្វីដែលលោក ឆាំង យុ និយាយនេះ មិនមានការពាក់ព័ន្ធទៅនឹងឯកសារទេ ហើយព្រះរាជអាជ្ញាមិនបានសួរទៅលោក ឆាំង យុ ដោយត្រឹមត្រូវទេ ។ មេធាវី ខណាវ៉ាស់ បានស្នើទៅអង្គជំនុំជម្រះឲ្យសួរទៅលោក ឆាំង យុ ឲ្យសួរឲ្យចំប្រធានបទ ។

ចៅក្រម និល ណុន យល់ព្រមទៅនឹងសំណើរបស់មេធាវី ខណាវ៉ាស ហើយបានបញ្ជាក់ទៅព្រះរាជអាជ្ញាថា បាន«ខ្ជះខ្ជាយ»ពេលវេលាជិតមួយម៉ោងហើយ ហើយចៅក្រមបានណែនាំទៅព្រះរាជអាជ្ញាឲ្យសួរ«ម្ដងទៀត» ទាក់ទងទៅនឹងអ្វីដែលពាក់ព័ន្ធ ។

ចាន់ តារាវស្ទី បន្តសួរទៅលោក ឆាំង យុ អំពីដំណើរការចងក្រងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ឆាំង យុ បានឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានឯកសារពីប្រភពជាច្រើន ហើយមកដល់ថ្ងៃនេះទទួលបានឯកសារមួយលានទំព័រ ។ លោកបានធ្វើសក្ខីកម្មទៀតថា លោកបានអានឯកសារទាំងអស់មុននឹងយកឯកសារនោះទៅចុះក្នុងបញ្ជី ។ លោកបានបញ្ជាក់ថា “ខ្ញុំអានឯកសារដូចញ៉ាំអាហារពេលព្រឹកអញ្ចឹង” ។ ក្រោយពីអានឯកសារចប់ហើយ លោកប្រគល់ឯកសារនោះទៅលោក វ៉ាន់ថាន់ ពៅដារ៉ា ដែលជាអនុប្រធានរបស់លោកដើម្បីយកទៅចម្លង និងចុះបញ្ជី ។

ក្រោយមក ព្រះរាជអាជ្ញាបានសួរសំណួរតែលោក ឆាំង យុ មិនយល់សំណួរហើយគាត់ក៏សួរទៅព្រះរាជអាជ្ញាវិញ តែត្រូវចៅក្រម និល ណុន និយាយកាត់ ។ ចៅក្រម និល ណុន ណែនាំលោក ឆាំង យុ ថា តួនាទីរបស់សាក្សី គឺដើម្បីឆ្លើយទៅនឹងសំណួរ មិនមែនសួរសំណួរទៅកាន់ព្រះរាជអាជ្ញាវិញទេ ។

ក្រោយមក លោក ឆាំង យុ បានបញ្ជាក់ឲ្យច្បាស់ថែមទៀតចំពោះអ្វីដែលមានការភ័ន្តច្រឡំខ្លះដោយ វ៉ាន់ថាន់ ពៅដារ៉ា ពេលដែលបានធ្វើសក្ខីកម្មកាលពីសប្តាហ៍មុន ។ ពេលលោក ឆាំង យុ និយាយបែបនេះធ្វើឲ្យមានការជំទាស់ពីមេធាវី ខណៈវ៉ាស់ ដែលអះអាងថា លោក ឆាំង យុ មិនអាចផ្តល់យោបល់ណាមួយទៅនឹងអ្នកដែលបានធ្វើសក្ខីកម្មមុនៗបានទេ ។ លោកអាចនិយាយតែដំណើរការឯកសារប៉ុណ្ណោះ ។ ក្រោយមក អង្គជំនុំជម្រះបានណែនាំទៅលោក ឆាំង យុ ឲ្យឆ្លើយខ្លីៗទៅនឹងសំណួរដែលបានសួរ ។

លោក ឆាំង យុ បន្តឆ្លើយដោយបញ្ជាក់ថា ឯកសារដែលប្រមូលបានដោយបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ពេលដែលបុគ្គលិកទាំងអស់ចុះទៅស្រាវជ្រាវតាមខេត្តនេះ គឺជាផ្នែកមួយនៃ“កិច្ចខំប្រឹងប្រែងស្រាវជ្រាវឯកសារ” ។ លោក ឆាំង យុ បានបញ្ជាក់ថា លោកដឹងពីឯកសារដែលប្រមូលបានទាំងអស់ ហើយឯកសារនីមួយៗ លោកបានអាន“ច្រើន”ដង ។ លោកមានចិត្តរីករាយនឹងការអានឯកសារ ជាពិសេសរូបថត លោកបញ្ជាក់ថា សម្រាប់លោក “បានអានឯកសារមួយសន្លឹកដូចជារើសបាយបានមួយគ្រាប់ក្នុងភក់កាលពីសម័យខ្មែរក្រហមអ៊ីចឹង គឺវាផ្អែមណាស់” ។

នៅពេលសួរអំពីជំនាញរបស់លោកក្នុងការអានឯកសារ លោក ឆាំង យុ បាននិយាយថា លោកមិនចាត់ទុកខ្លួនលោកជា“អ្នកជំនាញជាន់ខ្ពស់”ទេ តែលោកមានបទពិសោធន៍ជាច្រើនឆ្នាំធ្វើការជាមួយឯកសារ ។ លោកបាននិយាយថា លោកដឹងពីវប្បធម៌និងការប្រើប្រាស់ភាសាក្នុងឯកសារខ្មែរ

ក្រហម ដែលធ្វើឲ្យលោកអាចយល់ពីខ្លឹមសាររបស់ឯកសារនោះ ។ លោកអាចស្គាល់ឯកសារខ្មែរក្រហម“បានក្លាម” ដោយសារតែភាសាដែលបានប្រើប្រាស់ខុសពីភាសាដែលប្រើក្នុងសម័យផ្សេងៗ ។

លោក ឆាំង យុ បានបន្តទៀតថា ទាក់ទងទៅនឹងបញ្ហាឯកសារ មជ្ឈមណ្ឌលឯកសារកម្ពុជាចាត់ទុកថា ឯកសារដើម និងឯកសារចម្លងពីឯកសារដើម (ដូចជាសៀវភៅខ្មៅ) ជាឯកសារដើមក្នុងករណីដែលឯកសារដើមមានវត្តមាននៅបរទេស ។ លោក ឆាំង យុ បាននិយាយទៀតថា ឯកសារដើមមួយចំនួនមិនមានវត្តមាននៅប្រទេសកម្ពុជា តែមជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារថតចម្លង ដូច្នេះមជ្ឈមណ្ឌលឯកសារកម្ពុជាចាត់ទុកថា នោះគឺជាឯកសារដើម ។

ទាក់ទងទៅនឹងការបញ្ជាក់យថាភាពឯកសារកម្ពុជាប្រជាធិបតេយ្យ លោក ឆាំង យុ បានពន្យល់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានសិក្សាទៅលើចំនុចមួយចំនួនដូចជា ៖

១. ផ្តោតទៅលើពណ៌ក្រដាស និងកាលបរិច្ឆេទ

២. ហត្ថលេខា ឬឈ្មោះដែលរៀបរាប់នៅក្នុងក្រដាសនោះ

៣. ប្រធានបទដែលនិយាយនៅក្នុងឯកសារនោះ និង

៤. ភាសាដែលប្រើប្រាស់ ឬពាក្យពេចន៍ដែលប្រើនៅក្នុងឯកសារនោះ

លោក ឆាំង យុ បាននិយាយថា ដោយពិចារណាលើកត្តាខាងលើនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាអាចកំណត់អំពីយថាភាពរបស់ឯកសារបានដោយជឿជាក់ ។

តារាវស្មី បានបញ្ចប់សំណួររបស់ខ្លួន ហើយអង្គជំនុំជម្រះប្រកាសសម្រាកពេលព្រឹក ។ តែមុននឹងអង្គជំនុំជម្រះប្រកាសសម្រាក មេធាវីរបស់ អៀង សារី បានជូនដំណឹងទៅអង្គជំនុំជម្រះថា អៀង សារី សុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការ ។ អង្គជំនុំអនុញ្ញាត តែតម្រូវឲ្យប្រគល់លិខិតស្នើសុំជាលាយលក្ខណ៍អក្សរដោយភ្ជាប់ជាមួយនូវហត្ថលេខារបស់ជនជាប់ចោទផ្ទាល់ ។

ក្រោយពីសម្រាករួច សហព្រះរាជអាជ្ញាអន្តរជាតិ ថារិក អាប់ឌុលឡាក់ ចាប់ផ្តើមសួរទៅលោក ឆាំង យុ ។ ថារិក អាប់ឌុលឡាក់ ផ្តើមសំណួរអំពីប្រភពសំខាន់របស់ឯកសារដែលបានប្រគល់ជូនទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ឆាំង យុ បាននិយាយថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលឯកសារមកពីប្រភពជាច្រើននិងពីគ្រប់ក្រសួងរបស់រដ្ឋាភិបាលទាំងអស់ និងពីបុគ្គលផ្ទាល់រួមទាំងជនបរទេសផង ។ នៅពេលសួរអំពីឯកសារដើមនៅមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ បានឲ្យដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារថតចម្លង និងឯកសារដើមជាច្រើន តែសម្រាប់ឯកសារដែលថតចម្លងវិញមិនមានឯកសារដើមនៅប្រទេសកម្ពុជាទេ ។ ប្រទេសស៊ុយអ៊ែតមានឯកសារដើមជាច្រើន ហើយឯកសារថតចម្លងមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ទាក់ទងទៅនឹងឯកសារមកពីក្រសួងមហាផ្ទៃ លោក ឆាំង យុ បានឲ្យដឹងថា ឯកសារទាំងអស់នេះភាគច្រើនជាឯសារក្រដាស និងមានវីដេអូខ្លះៗ ព្រមទាំងរូបថតមួយចំនួន ។ លោកបានបន្តទៀតថា ប៉ែន យៀនិន ដាក់ឈ្មោះឯកសារនោះថា "សន្តិបាល" ព្រោះឯកសារនោះ គឺជាឯកសារផ្ទៃក្នុងទាក់ទងទៅនឹងឯកសារសន្តិសុខផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ពាក្យសន្តិបាលមាននៅលើឯកសារជាច្រើន ។ ឯកសារជាច្រើនត្រូវបានប្រមូលដោយមជ្ឈមណ្ឌលឯកសារកម្ពុជា តែឯកសារខ្លះខូចខាត និងបាត់ខ្លះហើយ ដូច្នេះលោកតែងតែទៅមើលទីតាំងប្រភពឯកសារនោះនិងរកមើលឯកសារផ្សេងទៀត ។

លោក ឆាំង យុ បានឲ្យដឹងទៀតថា ក្នុងឆ្នាំ១៩៨២ ឬ១៩៨៣ ឯកសារមកពីក្រសួងមហាផ្ទៃត្រូវបានរកឃើញនៅផ្ទះមួយនៅជិតផ្ទះរបស់អគ្គរដ្ឋទូតអាមេរិកសព្វថ្ងៃ ។ ឯកសារនោះក្រោយមកត្រូវបានបញ្ជូនទៅក្រសួងមហាផ្ទៃ ។ មិនមានព័ត៌មានច្បាស់លាស់ទេអំពីថា តើនរណានៅក្នុងផ្ទះនោះកាលពីរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកបានបញ្ជាក់ថា លោកស្គាល់បុគ្គលខ្លះដែលដឹកឯកសារនោះចេញពីផ្ទះទៅកាន់ក្រសួងមហាផ្ទៃ ហើយលោកក៏បានផ្តល់បញ្ជីឈ្មោះនេះទៅការិយាល័យសហចៅក្រមស៊ើបអង្កេតដែរ ។

នៅពេលសួរអំពីខ្លឹមសារទូទៅរបស់ឯកសារនៅក្រសួងមហាផ្ទៃ លោក ឆាំង យុ បាននិយាយថា ឯកសារនោះមានប្រវត្តិរូបពីរប្រភេទ ៈ ប្រវត្តិរូបរបស់អ្នកដែលជាប់ឃុំឃាំង និងឯកសាររបស់កម្មាភិបាលតែមិនត្រូវបានចាប់ខ្លួនទេ ។ ទាក់ទងទៅនឹងចម្លើយសារភាពពីក្រសួងមហាផ្ទៃ លោក ឆាំង យុ បានបញ្ជាក់ថា មានចម្លើយសារភាពចំនួន៤០០០ នៃអ្នកទោសចំនួន១២០០០នាក់ដែលបានជាប់នៅទួលស្លែង ។ តែនៅក្រសួងមហាផ្ទៃរកឃើញតែចម្លើយសារភាពតែ១០០០ប៉ុណ្ណោះ ហើយចម្លើយសារភាពនោះមានលក្ខណៈវែងជាងចម្លើយសារភាពដែលរកឃើញនៅទួលស្លែង ឯកសារនោះយកចេញពីគុកផ្សេងទៀតដែលមិនមែនជាគុកទួលស្លែង ។ លោកបាននិយាយទៀតថា ចម្លើយសារភាពខ្លះ គឺជារបស់កម្មាភិបាលជាន់ខ្ពស់របស់ខ្មែរក្រហមដូចជា កុយ ធួន ហើយមានគម្របខាងក្រៅដែលមិនមាននៅទួលស្លែងទេ ។ លោក ឆាំង យុ បានបន្តទៀតថា ចំណាររបស់ ឌុច ងាយស្រួលចំណាំណាស់ ព្រោះឯកសារនោះមានហត្ថលេខារបស់ ឌុច ផ្ទាល់ តែចំណាររបស់មេដឹកនាំផ្សេងទៀត មិនងាយចំណាំបានទេ ព្រោះអ្នកទាំងនោះប្រើឈ្មោះផ្សេងៗ ដូចជាប្រើឈ្មោះបដិវត្តន៍ជាដើម ។

មានចម្លើយសារភាពមួយមានចំណាររបស់មនុស្សប្អូនទៅប្រាំនាក់នៅលើគម្រប ដូចជាចំណាររបស់ ឌុច និង "ខៀវ" (សុន សេន) ។ ពាក្យសន្តិបាលនោះ គឺជាឯកសារដែលដាក់ឈ្មោះដោយលោក ប៉ែន យៀនិន ដែលចេះនិយាយភាសាខ្មែរយ៉ាងច្បាស់ ដូច្នេះគាត់អាចស្គាល់ពាក្យ"សន្តិបាល"

ដែលសរសេរនៅលើគម្របចម្លើយសារភាពនោះបាន ហើយក្រោយមកឯកសារទាំងអស់នោះត្រូវបាន ហៅថា ឯកសារសន្តិបាល ។

ក្រោយមក ថារិក អាប់ឌុលឡាក់ បានត្រលប់ទៅសួរពីឯកសារឆ្លើយឆ្លងដែលរកឃើញនៅក្នុងបណ្ណសាររបស់ក្រសួងមហាផ្ទៃ ។ លោក ឆាំង យុ បានបញ្ជាក់ថា មានឯកសារឆ្លើយឆ្លងច្រើនរួមមានកំណត់ហេតុកិច្ចប្រជុំរវាង អៀង សារី និងគណៈប្រតិភូបរទេស និងអត្ថបទឆ្លើយឆ្លងផ្សេងទៀត ព្រមទាំងសំបុត្ររបស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ។

លោក ឆាំង យុ បានឲ្យដឹងទៀតថា លោកចងចាំសំបុត្រមួយយ៉ាងច្បាស់សរសេរដោយកម្មាភិបាលខ្មែរក្រហមម្នាក់ដែលចង់រំលូតកូនចេញ ព្រោះស្ត្រីនោះជឿថា កូននៅក្នុងផ្ទៃនោះគឺជាកូនរបស់ "ខ្មាំង" ។ ស្ត្រីនោះបានរៀបរាប់នៅក្នុងសំបុត្រនោះថា គាត់បានប្រព្រឹត្តិ "ខុសសីលធម៌" និងគាត់ខ្លាចគេយកទៅសម្លាប់ ។ ក្រោយមកសំបុត្រនោះត្រូវបានចាប់បាន ហើយស្ត្រីនោះត្រូវបានចាប់ខ្លួនដោយកម្មាភិបាលខ្មែរក្រហម ។

ប្រធានបទដែលត្រូវពិភាក្សាក្រោយ គឺឯកសារដែលមានឈ្មោះថា "ឯកសារ លន់ នល់" ។ លោក ឆាំង យុ បានឲ្យដឹងថា លោកមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងពេលដែលលោកឃើញឯកសារទាំងនេះ ព្រោះឯកសារនោះនៅក្នុងប្រអប់មួយដែលមានឈ្មោះថា "រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ" ។ តែក្រោយពីបើកប្រអប់នោះរួចមកបែរជាឃើញមានឯកសារខ្មែរក្រហមទៅវិញ លោក ឆាំង យុ ជឿថាអ្នកដែលបិតផ្លាកនោះបិតខុសដោយអចេតនា ។ ក្រោយមក ឯកសារនោះត្រូវបានហៅដោយមជ្ឈមណ្ឌលឯកសារកម្ពុជាថា "ឯកសារ លន់ នល់" ។

ថារិក អាប់ឌុលឡាក់ បានសួរថាតើលោក ឆាំង យុ ជឿថាឯកសារមកពីក្រសួងមហាផ្ទៃគឺជាឯកសារដើមដែរឬទេ? លោក ឆាំង យុ បានបញ្ជាក់ទៀតថា ឯកសារទាំងនេះត្រូវបានជឿថាជាឯកសារដើមពីរបបកម្ពុជាប្រជាធិបតេយ្យដោយសារតែអាយុកាល ខ្លឹមសារ និងពាក្យពេចន៍ដែលប្រើនៅក្នុងឯកសារនោះ ។ លោកបានបញ្ជាក់ថា ឯកសារទាំងអស់នោះត្រូវបានយកទៅប្រៀបធៀបជាមួយឯកសារផ្សេងទៀតដែលជាឯកសារខ្មែរក្រហម ។

ក្រោយមក លោក ឆាំង យុ បានរៀបរាប់ពីដំណាក់កាលឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយរៀបរាប់ពីឯកសារដែលត្រូវឆ្លងកាត់តុរបស់លោកមុននឹងទៅបញ្ចូលទៅក្នុងទូ ។ មុននឹងទៅដល់ក្នុងទូ ឯកសារទាំងអស់ត្រូវបានចាត់ថ្នាក់ និងចុះកាតាឡុក ។ លោកបានបញ្ជាក់ទៀតថា នៅពេលដែលនរណាម្នាក់ប្រគល់ឯកសារមកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្រុមខាងឯកសារបានបង្កើតសំណុំដោយទុកឯកសារក្នុងប្រធានបទដូចគ្នា ។

លោកបានបន្ថែមទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាផ្ដល់ឯកសារថតចម្លងទៅអ្នកមកមើលឯកសារជាជាងផ្ដល់ការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធើណែត ព្រោះប្រជាជនកម្ពុជានៅជនបទមិនចេះប្រើកុំព្យូទ័រទេ ហើយប្រជាជនចង់យកឯកសារទៅជាមួយ ។

ត្រលប់មកនិយាយអំពីការស្រាវជ្រាវឯកសារពីបណ្ណសារដ្ឋានជាតិវិញ លោក ឆាំង យុ បានគូសបញ្ជាក់ថា លោកបានទៅបណ្ណសារដ្ឋានជាតិជាច្រើនលើកច្រើនសារ ព្រោះឯកសារខ្លះខូះចន្លោះ ហើយឯកសារខ្លះបាត់ ។ ឧទាហរណ៍ដូចជា លោកឃើញឯកសារជាច្រើនក្រោយពីអានសៀវភៅរបស់លោក ប៉ែន យៀនិន ហើយក្រោយមកគាត់បានប្រគល់ឯកសារទាំងនោះទៅអង្គភាពការពារក្ដីរបស់អង្គជំនុំជម្រះ ។ នៅបណ្ណសារដ្ឋានជាតិ លោកបានរកឃើញប្រភេទឯកសារជាច្រើនរួមទាំងសំណុំឯកសារផ្នែកពាណិជ្ជកម្ម មកពីក្រសួងពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យដែលនិយាយអំពីការធ្វើពាណិជកម្ម ដូចជាតម្លៃស្រូវអង្ករជាដើម ។ ឯកសារទាំងនេះ គឺជាឯកសារដើម ព្រោះអតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឈ្មោះ វ៉ាន់ រិទ្ធ អះអាងថា ឯកសារនោះគឺជាឯកសារដើមមុននឹងគាត់ស្លាប់ ។ លោក ឆាំង យុ ក៏បានបញ្ជាក់ដែរថា ឯកសារពាណិជ្ជកម្មភាគច្រើនជាឯកសារដែលនិយាយពីការបង្កបង្កើនផលស្រូវទូទាំងប្រទេសនៅរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រោយមក ថាវិក អាប់ឌុលឡាក់ បានស្នើទៅលោក ឆាំង យុ ឲ្យផ្ដល់យោបល់អំពីឯកសាររបស់ ដាវីដ ហក ដែលជាផ្នែកមួយនៃគណៈកម្មការស្រាវជ្រាវឯកសារកម្ពុជា ក្រោយរបបខ្មែរក្រហម ។ លោក ឆាំង យុ ឆ្លើយតបថា ឯកសារនេះរួមមានរូបថតពីគុកទួលស្លែង និងពីរណ្ដៅសាកសពផ្សេងៗ ។ រូបថតមកពីទួលស្លែង គឺជារូបថតដើមពីសម័យកម្ពុជាប្រជាធិបតេយ្យ ហើយ លោក ដាវីដ ហក ក៏បានថតរូបរណ្ដៅសាកសពច្រើនដែរ ។ ឯកសារទាំងអស់ដែលប្រមូលដោយ ដាវីដ ហក ត្រូវបានបញ្ជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ទាក់ទងទៅនឹងឯកសារដើមដែលរកឃើញនៅទួលស្លែង លោក ឆាំង យុ បានឲ្យដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានយកឯកសារដើមពីទួលស្លែងទេ តែបុគ្គលខ្លះបានផ្ដល់ឯកសារដើមពីទួលស្លែងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយឯកសារទាំងនោះត្រូវបានរក្សាទុកទៅក្នុងទូសុវត្ថិភាព ដែលអាចទប់ទល់ជាមួយអគ្គីភ័យបាន ។ លោកបានបន្តទៀតថា មជ្ឈមណ្ឌមឯកសារកម្ពុជាមានទំនាក់ទំនងការងារ និងវិជ្ជមានជាមួយសារមន្ទីរទួលស្លែង ។

លោក ឆាំង យុ បានរំឭកឡើងវិញថា មានពេលមួយ ដោយមានការអនុញ្ញាត លោកបានចូលទៅបោសសម្អាតបន្ទប់មួយដែលពេញដោយ«សំរាម» ។ នៅក្នុងបន្ទប់នោះ លោកបានឃើញឯកសារជាច្រើនដូចជា រូបថត និងប្រវត្តិរូបរបស់អ្នកទោសជិត៤០០ដែលគ្មាននរណាដឹងពីឯកសារនោះទេ ។ លោកបានបញ្ជាក់ថា ឯកសារខ្លះមកពីទួលស្លែងត្រូវបានរកឃើញនៅទីកន្លែងផ្សេងទៀត ដូចជា

នៅផ្ទះរបស់ឯកជនជាដើម ហើយឯកសារខ្លះទៀតបានបាត់បង់ ព្រោះកាលនោះការប្រមូលឯកសារមិនមែនជាអទិភាពចម្បងទេ ។ លោក ឆាំង យុ បានឲ្យដឹងទៀតថា ឯកសារមិនត្រូវបានឲ្យតម្លៃប៉ុន្មានទេក្រោយសម័យខ្មែរក្រហម ព្រោះកាលនោះប្រជាជនគិតពីរឿងអត់ឃ្លានច្រើនជាង ។ អំឡុងពេលនោះ ឯកសាររបស់ខ្មែរក្រហមហាក់បីដូចជា ការស្បែតចាស់ និងស្លឹកចេកអីចឹង ដោយយកទៅដើម្បីខ្ចប់នំនិងចេកជៀនជាដើម ។ លោកនិយាយថា ឯកសារទាំងអស់នោះងាយស្រួលនឹងបាត់បង់ណាស់ ។

## នួន ជា ហត់នឿយ និងស្នើទៅសម្រាក

សក្ខីកម្មរបស់លោក ឆាំង យុ សម្រាប់ព្រឹកនេះបានបញ្ចប់ ។ ជាធម្មតា មុននឹងសម្រាកមេធាវីរបស់ នួន ជា បានជូនដំណឹងទៅកាន់អង្គជំនុំជម្រះថា ជនជាប់ចោទ នួន ជា ចង់ទៅសម្រាកដោយសារបញ្ហាសុខភាព ។ អង្គជំនុំជម្រះបានយល់ព្រម និងទាមទារឲ្យមានលិខិតជាលាយលក្ខណ៍អក្សរ ។

## ព្រះរាជអាជ្ញាបញ្ចប់សំណួរទៅកាន់លោក ឆាំង យុ

ក្រោយពីសម្រាកថ្ងៃត្រង់ ថាវិក អាប់ឌុលឡាក់ បន្តសួរសំណួរទៅលោក ឆាំង យុ ដោយផ្តើមសួរអំពីឯកសារជាក់លាក់មួយចំនួនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយឯកសារនោះត្រូវបានបញ្ចាំងនៅលើអេក្រង់កុំព្យូទ័រនៃអង្គជំនុំជម្រះ ។

ថាវិក អាប់ឌុលឡាក់ បានសួរថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានជួយគ្រប់ភាគីទាំងអស់ស្រាវជ្រាវរកឯកសារដែរឬទេ? លោក ឆាំង យុ ឆ្លើយតបថា គ្រប់ភាគីទាំង មានថ្ងៃដែលត្រូវទៅរកឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយគ្រប់ភាគីទាំងអស់ត្រូវបានជួយដោយបុគ្គលិករបស់មជ្ឈមណ្ឌលមណ្ឌលឯកសារកម្ពុជា ។

នៅពេលបង្ហាញឯកសារទីមួយ លោក ឆាំង យុ បានឲ្យដឹងថា ចំណារនៅលើឯកសារនោះគឺជាសញ្ញាណលេខផ្ទៃក្នុងរបស់ឯកសារ ហើយនិងកាលបរិច្ឆេទដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ព្រះរាជអាជ្ញាបានបង្ហាញគម្របទំព័រខាងមុខរបស់សៀវភៅទង់បដិវត្តន៍ដែលលោក ឆាំង យុ បញ្ជាក់ថា នេះគឺជាឯកសារដែលស្កេនចេញពីឯកសារដើម ហើយគម្របរបស់ទស្សនាវដ្តីនេះមានពណ៌ក្រហម ។ លោក ឆាំង យុ បានផ្តល់សក្ខីកម្មថា លោកបានអានសៀវភៅទង់បដិវត្តន៍នោះ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានឯកសារដើមដែរ ចំណែកឯកសារទង់បដិវត្តន៍ដើមខ្លះដាក់តាំងនៅសារមន្ទីរទួលស្លែង ។ លោកបានបញ្ជាក់ថា លោកបានអានឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមាន ហើយពាក្យពេចន៍ដែលប្រើនៅក្នុងនោះ គឺជាពាក្យដែលបានប្រើកាលពីរបបខ្មែរក្រហម ពាក្យទាំងនោះមិនមានការប្រើប្រាស់នៅក្នុងសម័យនេះទេ ។

លោកបានផ្តល់សក្ខីកម្មទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារទង់បដិវត្តន៍ពី២០ទៅ២៥លេខក្នុងចំណោម៣៦លេខ។ ឯកសារដែលព្រះរាជអាជ្ញាបង្ហាញបន្ទាប់ គឺជាប្រវត្តិរូបរបស់អ្នកទោសម្នាក់ដែលប្រមូលចេញពីឯកសារសន្តិបាល ។

ឯកសារបង្ហាញផ្សេងទៀតគឺជាឯកសារប្រវត្តិរូបរបស់កម្ពុជាប្រជាធិបតេយ្យដែលលោក ឆាំង យុ ស្គាល់យ៉ាងច្បាស់។ លោកបាននិយាយថា ប្រវត្តិរូបនេះគឺជារបស់កម្មាភិបាលខ្មែរក្រហមម្នាក់មិនមែនជាអ្នកទោសទេ ហើយប្រវត្តិរូបនោះមានលក្ខណៈខុសគ្នា។ លោក ឆាំង យុ បានបញ្ជាក់ថា បើតាមលោកដឹងប្រវត្តិរូបទាំងនេះ គឺជាប្រវត្តិរូបដែលសរសេរខ្លួនឯង ដែលរៀបរាប់ពីប្រវត្តិនៃការចូលបដិវត្តន៍ ហើយត្រូវបានសរសេរដោយកម្មាភិបាលរៀងរាល់ប្រាំមួយខែម្តង ដោយកម្មាភិបាលខ្មែរក្រហមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ឯកសារទីប្រាំដែលត្រូវបង្ហាញបន្ត លោក ឆាំង យុ បញ្ជាក់ថា ជារូបដែលចម្លងចេញពីឯកសារដើមមកពីបណ្ណសារដ្ឋានជាតិ ។ លោកបានអានបន្ទាត់ទីមួយនៃឯកសារនោះ ដែលបានរាយការណ៍ជូន «បងហែម» អំពីកិច្ចប្រជុំរវាងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានិងគណៈប្រតិភូចិន ។

ឯកសារទីប្រាំមួយដែលបង្ហាញនោះ លោក ឆាំង យុ ស្គាល់ថា ជារបាយការណ៍មកពីក្រសួងពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ ដែលរៀបរាប់ពីឈ្មោះមួយចំនួនដែលនឹងត្រូវបញ្ជូនទៅអប់រំក្នុងនោះមានបុគ្គលម្នាក់ខ្ជិលហើយមិនចង់ធ្វើការ ។ លោកបាននិយាយថា ឯកសារនោះរកបាននៅទួលស្លែង ហើយឯកសារដែលមកពីទីកន្លែងផ្សេងៗត្រូវបានរកឃើញនៅទួលស្លែង ។ ឯកសារទីប្រាំពីរដែលដាក់បង្ហាញត្រូវបានលោក ឆាំង យុ ស្គាល់ថា ជាឯកសារដែលបានបញ្ជូនទៅ«មន្ទីរ៨៧០» ។ លោកបានបង្ហាញថា ទោះបីជាឯកសារដែលបង្ហាញនោះគឺជាឯកសារដែលស្កេនក៏ដោយតែលោកមានឯកសារដើមដោយផ្ទាល់ខ្លួន ។

ឯកសារទីប្រាំបីដែលបង្ហាញ និងសរសេរជាភាសាអង់គ្លេសមានចំណងជើងថា «ចម្លើយសារភាពរបស់គិញវៀតណាម» ។ លោក ឆាំង យុ បានឆ្លើយថា លោកអាចអានឯកសារនោះបាន តែលោកចង់អានជាភាសាខ្មែរ ព្រោះនេះជាភាសាកំណើតរបស់គាត់ ។ លោកនិយាយថា ម្តាយរបស់លោកគឺជាខ្មែរ ហើយប្រហែលពេលនេះ ម្តាយរបស់លោកក៏កំពុងតែមើលទូរទស្សន៍ដែរ ដូចនេះលោកមិនចង់ឲ្យម្តាយរបស់លោកមានការភ័ន្តច្រឡំទេ ។ លោក ឆាំង យុ បាននិយាយថា ឯកសារមកពីប្រទេសស៊ុយអ៊ែត ត្រូវបានប្រគល់មកមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ២០០៧ ។

ឯកសារទីប្រាំបួនដែលដាក់បង្ហាញ គឺជារបាយការណ៍ដែលភូមិភាគបូព៌ាបញ្ជូនទាក់ទងទៅនឹងសកម្មភាពរបស់សត្រូវនៅតំបន់នោះ ។ លោក ឆាំង យុ បានរៀបរាប់ពីស្ថាប័នដែលទទួលរបាយការណ៍នោះគឺ «មន្ទីរ៨៧០» ដែលជា«លេខកូដសម្ងាត់»របស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ។

ឯកសារទីដប់ដែលបានបង្ហាញ គឺជាឯកសារដែលយកចេញពីសំណុំរបស់ឯកសារ «លន់ នល់» មានចំណងជើងថា «របាយការណ៍ប្រចាំអាទិត្យរបស់គណៈតំបន់៥» ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ ១៩៧៧ ។ លោក ឆាំង យុ បានរៀបរាប់ថា តំបន់៥ គឺជាកន្លែងដែលគាត់រស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលកាលនោះស្ថិតក្នុងខេត្តបាត់តំបង ហើយសព្វថ្ងៃនេះស្ថិតក្នុងខេត្តបន្ទាយមានជ័យ ។ ឯកសារនោះប្រហែលជាបញ្ជូនទៅលេខាភូមិភាគពាយ័ព្យ និងមន្ទីរ៥៦០ តែលោកមិនដឹងថាមន្ទីរនោះចង់សំដៅដល់កន្លែងណាទេ ។

ឯកសារទីដប់មួយដែលដាក់បង្ហាញ គឺជារបាយការណ៍ខែឧសភា ឆ្នាំ១៩៧៧ ហើយត្រូវបានបញ្ជូនទៅមន្ទីរ៥៦០ ។

ឯកសារទីដប់ពីរដែលបានបង្ហាញ គឺជាឯកសារដែលមានរូបភាពមិនសូវច្បាស់ដែលជាហេតុធ្វើឲ្យមើលឈ្មោះសាក្សីមិនសូវច្បាស់ ។ លោក ឆាំង យុ ស្គាល់ឯកសារនោះថា ជាឯកសារដើមរបស់ទូរសាររបស់ខ្មែរក្រហម ។ នៅពេលដែលលោកត្រូវបានសួរអំពីចំណារនៅលើឯកសារនោះ មេធាវីខាណាវ៉ាស់ របស់ អៀង សារី បានងើបឈរនិងបដិសេធ ព្រមទាំងបានអះអាងថា ព្រះរាជអាជ្ញាបានប្រាស់សំណួរចាកពីដែនកំណត់របស់អង្គជំនុំជម្រះក្នុងការសួរសំណួរហើយ ហើយលោក ឆាំង យុ អាចឆ្លើយបានត្រឹមតែទាក់ទងទៅនឹងយថាភាពរបស់ឯកសារប៉ុណ្ណោះ ។

ថារិក អាប់ឌុលឡាក់ បន្តសំណួរទៀតដោយបង្ហាញឯកសារទីដប់បីរបស់គាត់ ។ លោក ឆាំង យុ ស្គាល់ឯកសារនោះមានចំណងជើងថា «កិច្ចប្រជុំគណៈអចិន្ត្រៃយ៍» ដែលរៀបរាប់អំពីកំណត់ហេតុកិច្ចប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជា ។ លោកបាននិយាយថា ឯកសារនេះលោកទទួលបានពីលោក ប៉ិន យៀនិន ហើយនៅលើឯកសារនោះមានចំណារថា «ប៉ិន» ។ មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានឯកសារថតចម្លងពី ប៉ិន យៀននិន ប៉ុន្តែនៅតែមានការមិនយលស្របគ្នាក្នុងចំណោមអ្នកស្រាវជ្រាវផ្សេងៗទាក់ទងទៅនឹងប្រភពរបស់ឯកសារនោះ និងនៅតែមានការមិនស្របគ្នាថា តើនរណាជាអ្នកមានឯកសារដើមទាំងអស់នេះ?

ថារិក អាប់ឌុលឡាក់ បានសួរទៅលោក ឆាំង យុ តើមានដែលមានការសង្ស័យអំពីយថាភាពឯកសាររបស់កម្ពុជាប្រជាធិបតេយ្យដែរឬទេ? លោក ឆាំង យុ បានបញ្ជាក់ថា លោកមានការសង្ស័យតែឯកសារមួយប៉ុណ្ណោះ ទាក់ទងទៅនឹងការចាប់ជម្រិតជនបរទេស ក្នុងឆ្នាំ១៩៩៤ ដោយកង

កម្លាំងខ្មែរក្រហម ។ លោកបានបញ្ជាក់ថា លោកមិនទទួលយកឯកសារនោះទេ ព្រោះភាសាដែលប្រើនៅក្នុងឯកសារនោះ មិនស៊ីគ្នាទៅនឹងពាក្យពេចន៍ដែលខ្មែរក្រហមបានប្រើប្រាស់ ហើយអ្នកដែលផ្ដល់ឯកសារនោះមិនបានប្រាប់ពីប្រភពរបស់ឯកសារនោះទេ ។ ថាវិក អាប់ឌុលឡាក់ បានបញ្ចប់សំណួរត្រឹមនេះ ។

## *ភាគីដើមបណ្ដឹងរដ្ឋប្បវេណីសួរទៅលោក ឆាំង យុ*

ក្រោយពីសម្រាក ភាគីដើមបណ្ដឹងរដ្ឋប្បវេណីចាប់ផ្ដើមសួរទៅលោក ឆាំង យុ ។ លោក ឆាំង យុ បានឆ្លើយទៅនឹងសំណួររបស់ ពេជ អង្គ ថា គោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺដើម្បី“បង្រួបបង្រួមជាតិ” ហើយដើម្បីធ្វើដូច្នេះ យើងត្រូវតែ“ស្វែងរកការពិត” ។

មេធាវី ខណាវ៉ាស់ បានជំទាស់ទៅនឹងអ្វីដែល ពេជ អង្គ បានសួរ ។ មេធាវីរូបនោះបានបញ្ជាក់ថា ភាគីដើមបណ្ដឹងរដ្ឋប្បវេណី កំពុងតែសួរនាំអំពីយុត្តិធម៌ និងការបង្រួបបង្រួមជាតិហើយ ។ ការជំទាស់នេះត្រូវបានយល់ស្របដោយអង្គជំនុំជម្រះ ហើយចៅក្រម និល ណុន បានណែនាំដល់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី ឲ្យសួរតែទាក់ទងទៅនឹងឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាប៉ុណ្ណោះ ។

លោក ពេជ អង្គ បានបន្តសួរទៅលោក ឆាំង យុ ថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាចាត់ទុកខ្លួនឯងថា “កំពុងស៊ើបអង្កេត”បទឧក្រិដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? លោក ឆាំង យុ បានឆ្លើយថា លោកមិនអាចឆ្លើយសំណួរនេះត្រឹមតែ “បាទ” ឬ “ទេ” បាននោះទេ តែលោកចាត់ទុកកិច្ចការទាំងមូលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតប្រវត្តិសម័យកម្ពុជាប្រជាធិបតេយ្យ ។ លោកបានបញ្ជាក់ទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនមានអំណាចផ្លូវច្បាប់ដើម្បីធ្វើការស៊ើបអង្កេតទេ ។

លោក ឆាំង យុ ចង់បញ្ជាក់ឲ្យច្បាស់ម្ដងទៀត នូវអ្វីដែលលោកអនុប្រធានរបស់លោក គឺលោក វ៉ាន់ថាន់ ពៅដារ៉ា ដែលបានប្រើពាក្យ“វិភាគ”ចំពោះឯកសារ ។ លោក ឆាំង យុ បានបកស្រាយថា ពាក្យនេះដោយសារតែមានការភ័ន្តច្រឡំនឹងពាក្យនៅក្នុងភាសាខ្មែរ ។ លោក ឆាំង យុ បានឲ្យដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រមូលនិងអានឯកសារ ដើម្បីឲ្យយល់ពីប្រវត្តិកម្ពុជាប្រជាធិបតេយ្យ តែលោកមិនប្រើពាក្យ “វិភាគ”ទេ ។

លោក ឆាំង យុ បានបន្តផ្ដល់សក្ខីកម្មថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនប្រមូលឯកសារដែលសំខាន់ៗទេ គឺប្រមូលឯកសារណាដែលពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកបានបញ្ជាក់ទៀតថា តាមចាំ លោកបានអានឯកសារជាច្រើន តែលោកមិននឹកឃើញថា មានឯកសារណាខ្លះទេ បើសិនជាឃើញឯកសារនោះ លោកអាចនឹកឃើញ ។

លោក ពេជ អង្គ បន្តសួរទៅលោក ឆាំង យុ អំពីឯកសារដែលគាត់ចម្លងចេញពីគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា តែត្រូវបានជំទាស់ ព្រោះលោកតម្រូវឲ្យបង្ហាញឯកសារនោះ ហើយលោក ពេជ អង្គ បានបន្តសួរសំណួរទៅមុខទៀត ។

ក្រោយពីសួរសំណួរផ្សេងទៀត លោក ឆាំង យុ បានផ្តល់សក្ខីកម្មថា មជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ឯកសារដោយឥតគិតថ្លៃទៅគ្រប់ភាគីទាំងអស់របស់សាលាក្តីខ្មែរក្រហមនេះ «ខ្ញុំផ្តល់ឯកសារទាំងអស់ដែលស្នើសុំ.... ខ្ញុំព្យាយាមធ្វើជាស្ថាប័នមួយមិនលំអៀង» ។

ក្រោយមក លោក ឆាំង យុ ត្រូវបានសួរថា ហេតុអ្វីបានជាបារាំងមិនបានផ្តល់ឯកសារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា? លោក ឆាំង យុ បានឲ្យដឹងថា «បារាំងជាប្រទេសមួយយ៉ាប់ណាស់ដែលមិនរវីរវល់»នឹងការចងក្រងឯកសាររបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ លោក ឆាំង យុ បានបញ្ជាក់ទៀតថា លោកមានការ«ភ្ញាក់ផ្អើល»នៅពេលដែលបារាំងជាប្រទេសសហការផ្តល់ជំនួយមួយមកសាលាក្តីខ្មែរក្រហមនេះ ។

ត្រង់ចំណុចនេះ អង្គជំនុំជម្រះបានជំទាស់ម្តងទៀត ហើយបានស្តីបន្ទោសលោក ពេជ អង្គ ថា សំណួរនេះមិនចំប្រធានបទទេ ហើយថា ការដែលសុំពេលបន្ថែមទៀតនោះមិនជាការសមស្របទេ ។

ក្រោយមក មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនាំមុខ អេលីហ្សាប៉ែត ស៊ីម៉ូណូហ្វត បានសួរទៅលោក ឆាំង យុ អំពីអ្វីដែលគាត់ធ្លាប់ថ្លែងទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេតដោយបញ្ជាក់ថា ក្នុងទសវត្សរ៍៩០ លោក និងបងស្រីរបស់លោកទទួលការគំរាមពី អៀង ធីរិទ្ធ ។

សំណួរនេះធ្វើឲ្យក្រុមការពារក្តីរបស់ អៀង សារី ជំទាស់ដោយអះអាងថា សំណួរនេះមិនទាក់ទងទៅនឹងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។ មេធាវី ខាណារ៉ាស បានអះអាងថា អង្គជំនុំជម្រះមិនអាចអនុញ្ញាតឲ្យភាគីណាមួយសួរពីប្រធានបទតាមចិត្តនោះទេ បើមិនដូច្នេះទេ សវនាការនេះនឹងជា«រទេះភ្លើងដែលរត់»មិនមានទិសដៅជាមិនខាន ។

អេលីហ្សាប៉ែត ស៊ីម៉ូណូហ្វត បានឆ្លើយតបវិញថា អ្វីដែលលោក ឆាំង យុ ធ្លាប់និយាយ គឺពាក់ព័ន្ធទៅនឹងកិច្ចការឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីផ្តល់មកកាន់សាលាក្តីខ្មែរក្រហមនេះ ។ អង្គជំនុំជម្រះបានជំទាស់ទៅនឹងអ្វីដែលមេធាវី ខាណារ៉ាស់ បាននិយាយ ហើយចៅក្រម និល ណុន បានប្រាប់ទៅលោក ឆាំង យុ ឲ្យឆ្លើយសំណួរ ។ លោក ឆាំង យុ បានឆ្លើយថា មានគេគំរាមមកបងស្រីរបស់លោកប្រហែលជាមកពីការចងក្រងឯកសារនេះ ហើយកាលនោះបងស្រីរបស់លោកបានមកប្រាប់លោកឲ្យឈប់ធ្វើកិច្ចការនេះដើម្បីសុវត្ថិភាពទាំងអស់គ្នា ។ បន្ទាប់មក លោក ឆាំង យុ

បានបកស្រាយថា លោកមិនបញ្ឈប់កិច្ចការរបស់លោកទេ ព្រោះលោកមានជំនឿថា ការស្វែងរកការបង្រួបបង្រួមនៅកម្ពុជា គឺជាកិច្ចការសំខាន់ណាស់ ។

អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត បានសួរទៅលោក ឆាំង យុ អំពីការតាំងចិត្តរបស់លោកក្នុងការវាយប្រឆាំងនិងនិទណ្ឌភាពដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើ ។ លោកបានឆ្លើយថា គោលបំណងទាំងនេះមិនប៉ះពាល់ដល់កិច្ចការប្រមូលឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ ហើយដើម្បីធានាបាននូវកិច្ចការនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានខិតខំរក្សាឯកសារក្នុងសភាពដើម ដូច្នេះឯកសារទាំងអស់អាចយកបានដោយត្រឹមត្រូវ ។

លោក ឆាំង យុ បានបញ្ជាក់ថា ឯកសារមកពីប្រភពដទៃទៀតរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ នៅរាយពាសពេញក្នុងការិយាល័យ ព្រោះឯកសារនោះ គឺជារបាយការណ៍ដែលត្រូវបានបញ្ជូនពីក្រសួងមួយទៅក្រសួងមួយទៀត ។ លើសពីនេះទៅទៀត លោកមានប្រសាសន៍ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលឯកសារទាំងអស់ទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ព្រោះរាល់ព័ត៌មានទាំងអស់សុទ្ធតែមានសារៈសំខាន់ទាំងអស់ ។ លោកបានបន្តថា ការប្រមូលឯកសារឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជាចម្រៀង ហើយនេះគឺជាស្នាដៃរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

នៅពេលសួរអំពីដំណើរការដែលក្រុមការពារក្តី អាចចូលទៅមើលឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ បានឆ្លើយថា ភាគីការពារក្តីអាចចូលទៅមើលឯកសារនៅក្នុងបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា តែមិនត្រូវអនុញ្ញាតិយកម្ហូបអាហារ និងភេសជ្ជៈទៅជាមួយទេ ដើម្បីការពារកុំឲ្យមានការខូចខាតដល់ឯកសារ ។

អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត បានសួរថា តើភាគីការពារក្តីពេញចិត្តទៅនឹងការទទួលបានឯកសារចម្លងចេញពីឯកសារដើមឬទេ? សំណួរនេះធ្វើឲ្យក្រុមការពារក្តីរបស់ អៀង សារី ជំទាស់ព្រមទាំងបានអះអាងថា ខ្លួន“សូមធ្វើការជំទាស់ទាំងស្រុង” ។ អង្គជំនុំជម្រះគាំទ្រការជំទាស់របស់មេធាវី ខាណាវ៉ាស ហើយក្រោយមក អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត បានសួរសំណួរចុងក្រោយរបស់ខ្លួនអំពីកិច្ចព្រមព្រៀងរវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ឆាំង យុ បានឆ្លើយថា មកដល់ពេលនេះ ការធ្វើកិច្ចការជាមួយគ្រប់ភាគីទាំងអស់មានលក្ខណៈវិជ្ជមាន និងល្អ ។

ចៅក្រម និល ណុន បានប្រកាសបញ្ចប់សម្រាប់ថ្ងៃនេះដោយបញ្ជាក់ថា ក្រុមការពារក្តី និងត្រូវផ្តល់ជូនចំនួនពីរថ្ងៃ ដើម្បីសួរទៅកាន់លោក ឆាំង យុ ។ សវនាការនឹងបន្តនៅថ្ងៃស្អែកវេលាម៉ោង ៩:០០ ។

**-ចប់-**